ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខ: ៦២១៩ ស្ទួន........ សហអ

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

<u>កម្មវត្ថុ:</u> *របាយការណ៍នៃកិច្ចប្រជុំប្រចាំខែកញ្ញា រវាង DICO និង ភ្នាក់ងារអនុវត្តន៍គម្រោង* IAs (Implementing Agencies) ។

<u>យោង:</u> *- លិខិតរបស់ DICO លេខ: ១១៥ សហអ ចុះថ្ងៃទី ២១ មេសា ២០១១*
*- លិខិតអញ្ជើញ លេខ: ៣៩១៧ ពណ.សហអ ចុះថ្ងៃទី ០៦ កញ្ញា ២០១១*

*តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព និង រាយការណ៍ ជូន* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបថា: កាលពីថ្ងៃទី ០៩ កញ្ញា ២០១១ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) បានរៀបចំកិច្ចប្រជុំប្រចាំខែសីហា រវាង DICO និង IAs ក្នុងគោលបំណងស្វែងយល់អំពីការប្រឈម, ភាពងាយស្រួល និង ផ្សព្វផ្សាយនូវលទ្ធផលនានាដែលកើតចេញពីការអនុវត្តន៍គម្រោង TDSP ។*

*ព្រមជាមួយគ្នានោះ DICO ក៏បានធ្វើការផ្សព្វផ្សាយអំពី "<u>ដំណើរការក្នុងការត្រួតពិនិត្យ និងវាយតម្លៃ M&E Procedures (Monitoring and Evaluation)</u>" ឲ្យដល់ភ្នាក់ងារអនុវត្តន៍គម្រោងទាំងអស់ផងដែរ ។ ផ្នែកហិរញ្ញវត្ថុរបស់ DICO ក៏បានបណ្តុះបណ្តាលអំពីការប្រប្រាស់បេឡា, ការចុះបញ្ជីគណនេយ្យ និងការកែសម្រួល SFMM ។*

*ខ្ញុំបាទសូមធ្វើការសង្ខេប នូវចំណុចសំខាន់ៗនៅក្នុងកិច្ចប្រជុំប្រចាំខែសីហា ២០១១ នេះ មានដូចខាងក្រោម៖*

១)- ដើម្បីឲ្យការអនុវត្តន៍គម្រោងមានភាពរលូន DICO បានបង្កើត និងធ្វើការផ្សព្វផ្សាយនូវបញ្ជី Check List (before and after the events) ដែលបញ្ជី Check List នេះ ភ្នាក់ងារអនុវត្តន៍គម្រោងទាំងអស់ ត្រូវអនុវត្តនៅមុនពេលរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា និងទស្សនៈកិច្ចសិក្សា ហើយនិងក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល, សិក្ខាសាលា និងទស្សនៈកិច្ចសិក្សា របស់ខ្លួន ។

២)- ការផ្សព្វផ្សាយអំពី Monitoring and Evaluation Procedures:

DICO បានធ្វើការផ្សព្វផ្សាយនូវនិតិវិធីក្នុងការត្រួតពិនិត្យ និងវាយតម្លៃនៅនៅក្នុងគម្រោងនីមួយៗ ហើយនិតិវិធីទាំងនោះ រួមមានៈ

- ✓ គំនិតទូទៅនៃការត្រួតពិនិត្យនិងវាយតម្លៃ សំរាប់គម្រោង
- ✓ គំរូផែនការការងារ
- ✓ ទម្រង់សំរាប់ចុះត្រួតពិនិត្យ
- ✓ គំរូរបាយការណ៍វឌ្ឍនៈភាពប្រចាំខែ (ថ្មី) ដែលងាយយល់ជាងមុន និងងាយស្រួលបំពេញជាងមុន
- ✓ ទម្រង់គំរូនៃការវាយតម្លៃវគ្គបណ្តុះបណ្តាល/សិក្ខាសាលា (Pre-test and Post-test Form)
- ✓ របាយការណ៍វឌ្ឍនភាពប្រចាំខែត្រូវផ្ញើមក DICO នៅក្នុង សប្តាហ៍ទី២ រៀងរាល់ខែ មន្ត្រី -LO របស់ DICO ត្រូវតាមដានរឿងនេះ
- ✓ DICO នឹងបញ្ជូនក្រុម M&E ចុះទៅធ្វើការជាមួយ IAs នៅ សប្តាហ៍ក្រោយ, ដូច្នេះសូមជួយសហការណ៍

៣)- DICO ក៏បានធ្វើការផ្សព្វផ្សាយអំពីការសម្រួលទៅលើ SFMM (Supplement Financial Management Manual) ទៅជូន IAs ទាំងអស់ ។

៤)- ការផ្សព្វផ្សាយអំពីបញ្ជី List of standards estimated cost: NOL ដែលធនាគារពិភពលោកបានផ្តល់ឲ្យ គឺមានលក្ខខ័ណ្ឌមួយចំនួន ដែលមានចែងនៅក្នុងបញ្ជីខាងលើនេះ ។ បញ្ជីនេះ គឺជាស្តង់ដារតម្លៃ ដែលធនាគារពិភពលោកអនុញ្ញាត ក្នុងការអនុវត្តន៍ផែនការបណ្តុះបណ្តាល, សិក្ខាសាលា និងទស្សនៈកិច្ចសិក្សានៅក្នុងកម្មវិធី TDSP ប្រចាំត្រីមាសទី៣ និង ត្រីមាសទី៤ ឆ្នាំ ២០១១ ។ ដូច្នេះគ្រប់ IAs ទាំងអស់ ត្រូវ អនុវត្តតាមស្តង់ដារតម្លៃ

នេះឲ្យបានត្រឹមត្រូវ ។ តាមការស្នើរបស់ធនាគារពិភពលោក DICO នឹងបញ្ជូនមន្ត្រីទៅចូលរួមគ្រប់វគ្គបណ្តុះបណ្តាល ដែលរៀបចំឡើងដោយ IAs ។

៥)- ផ្នែកហិរញ្ញវត្ថុរបស់ DICO បានបណ្តុះបណ្តាលនិងផ្សព្វផ្សាយ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងគម្រោង ដែលមានចំណុចសំខាន់ៗដូចខាងក្រោម:

- គំរូលិខិតតែងតាំងមន្ត្រីបង្គោល
- គំរូលិខិតសុំបង្កើតបេឡាសាច់ប្រាក់ (Petty Cash)
- Payment Request to DICO
- Petty Cash Receipt Voucher
- Petty Cash Payments Request
- Petty Cash Payment Voucher
- Monthly Petty Cash Book
- Petty Cash Replenishment
- Agenda and Schedule – Workshop
- Advance Request - WPBP for Workshop
- Liquidation of Advances to Workshop Report
- DSA Advance Request for Workshop
- Liquidation of DSA for attending Workshop
- DSA - Payments on Overseas TWST
- Fixed Asset Register
- Request for Quotation - Sample for IA's
- អ្វីដែលត្រូវចងចាំនៅក្នុងផ្នែកនេះគឺថា Liquidating ត្រូវធ្វើឲ្យហើយក្នុងរយៈពេល ១០ ថ្ងៃ មុននឹងអាចស្នើសុំ Cash Advance Request សំរាប់សកម្មភាពឬសិក្ខាសាលាមួយផ្សេងទៀត ។

៦)- ពាក្យក្រើនរំលឹកមួយចំនួន (A few words of reminding): ក្នុងគោលបំណងជៀសវាងនូវកំហុសនានាក្នុងការអនុវត្តន៍គម្រោង DICO បានធ្វើការក្រើនរំលឹកនូវចំណុចមួយចំនួនដូចមានខាងក្រោមៈ

- ✓ IAs នីមួយៗត្រូវគោរពឲ្យបានខ្ជាប់ខ្ជួននូវបែបបទ និងនិតិវិធីក្នុងការចំណាយ ហើយត្រូវប្រកាន់ខ្ជាប់នូវ SFMM (Supplementary Financial Management Manual)
- ✓ DICO នឹងត្រួតពិនិត្យយ៉ាងតឹងរឹងនូវរាល់ការចំណាយទាំងអស់ឲ្យសមស្របទៅតាម SFMM
- ✓ ត្រូវមានអភិបាលកិច្ចល្អ ដោយមិនត្រូវបំប៉ោងតម្លៃខុសពីការពិត
- ✓ សូមចងចាំថា នឹងមានការត្រួតពិនិត្យចំនួន ៥ ដំណាក់កាលគឺ (១)DICO (២) Auditor (៣) World Bank (៤) Ministry of Economy and Finance (៥( Anti-Corruption Unit
- ✓ ប្រសិនបើគេរកឃើញកំហុស គេនឹងចាត់វិធានការណ៍យ៉ាងតឹងរឹងដូចខាងក្រោម:
    - ο គេនឹងបញ្ជូនសវនកម្មពិសេសមួយ មកធ្វើការត្រួតពិនិត្យរាល់ការចំណាយទាំងអស់នៅក្នុងគម្រោង
    - ο គេនឹងប្រកាសថាយើងធ្វើកំហុសក្នុងផ្នែកលទ្ធកម្ម
    - ο គេនឹងផ្អាកគម្រោងជាបណ្តោះអាសន្ន
    - ο គេនឹងឲ្យយើងសងប្រាក់ ទៅតាមការដែលគេរកឃើញកំហុស
    - ο គេនឹងដាក់គម្រោងទៅក្នុងបញ្ជីខ្មៅ ដែលគេនឹងពិនិត្យតាមដានយ៉ាងតឹងរឹង

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ កញ្ញា ២០១១

**ប្រធាននាយកដ្ឋាន**

ឈៀង ពេជ្រ

<u>ចម្លងជូន:</u>

- ឯកឧត្តម ប៉ាន សូរស័ក្តិ
- ឯកឧត្តម ឌិត ទីណា
- ឯកឧត្តម សុខ សុភ័ក្រ្ត
- គ្រប់ ភ្នាក់ងារអនុវត្តន៍គម្រោង
- ឯកសារ - កាលប្បវត្តិ